# កំណត់ហេតុប្រជុំប្រចាំត្រីមាស
# ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ

កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD) ប្រព្រឹត្តទៅរយៈពេលមួយថ្ងៃ នាថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១៧ នៅអគារ Development Innovation ដែលមានសមាជិក WGPD និងក្រុមប្រឹក្សាស្រុកបានចូលរួមសរុប ៤៩ ស្រី ១៣ នាក់  កិច្ចប្រជុំនេះ មានគោលបំណងដូចខាងក្រោម៖

១. ធ្វើបច្ចុប្បន្នភាពសមាជិកWGPDអំពីវឌ្ឍនភាព និងផែនការការងាររបស់ WGPDកាលពីត្រីមាសលើកមុន
២. ពង្រឹងការយល់ដឹងរបស់សមាជិក WGPD អំពី៖ (ក) ក្របខ័ណ្ឌគុណតម្លៃនៃការរៀនសូត្រ និង (ខ)គោលការណ៍បច្ចេកទេសនៃដំណើរការ និងយន្តការសម្រាប់ធ្វើផែនការអភិវឌ្ឍ និងផែនការវិនិយោគថ្នាក់ក្រោមជាតិ
៣.បង្ហាញនូវភាពខ្វះចន្លោះនៃគោលនយោបាយ និងផ្តល់អនុសាសន៍លើករណីសិក្សាចំនួន ៧ ដែលពាក់ព័ន្ធទៅនឹងកំណែទម្រង់គោលនយោបាយ និងការអនុវត្តនៅកម្ពុជា

ជាកិច្ចចាប់ផ្តើមនៃកិច្ចប្រជុំលោក **ជា វ៉ាន់ថា** ជាប្រធានគណៈកម្មាធិការដឹកនាំនៃ WGPD និងជានាយកប្រតិបត្តិអង្គការ API បានថ្លែងអំណរគុណដល់អ្នកចូលរួមដែលមានវត្តមានក្នុងកិច្ចប្រជុំនេះ និង អង្គការ PACT ក៏ដូចជាអង្គការAPI ចំពោះការគាំទ្រកន្លងមក និងបានសង្ខេបអំពីការសម្រេចបានមួយចំនួនរបស់ WGPD និង ការវិវត្តថ្មីៗនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) នៅថ្នាក់ជាតិ។ លោក ក៏បានពន្យល់អំពីគោលបំណងនៃកិច្ចប្រជុំនេះដល់អ្នកចូលរួមទាំងអស់ផងដែរ និងជាចុងក្រោយ លោកបានថ្លែងបើកកិច្ចប្រជុំនេះ ។

## ផ្នែកទី១៖ បទបង្ហាញអំពីបច្ចុប្បន្នភាពដំណើរការការងាររបស់WGPDកាលពីត្រីមាសមុន

នៅក្នុងផ្នែកទី ១ នេះ ធ្វើបទបង្ហាញដោយ លោក **ជួន ឈាន់** ជាអ្នកសម្របសម្រួលរបស់ WGPD ។ មុននឹងធ្វើបទបង្ហាញ លោកបានពន្យល់ដល់អ្នកចូលរួមអំពីវិធីសាស្ត្រ នៅក្នុងការចែករំលែកឯកសារទៅដល់សមាជិក WGPD ទាំងអស់ និងបានពន្យល់បន្ថែមដោយសង្ខេបអំពីពង្រាងផែនការអនុត្ត ៣ ឆ្នាំ (IP3-III) ដែលលោក ជា វ៉ាន់ថា បានការលើកឡើងនៅពេលថ្លែងបើកកិច្ចប្រជុំនេះ។ បន្ទាប់មក លោក ជួន ឈាន់ ក៏ធ្វើបទបង្ហាញអំពីបច្ចុប្បន្នភាពពីដំណើរការការងាររបស់ WGPD កាលពីត្រីមាសមុន។ បទបង្ហាញនេះ ត្រូវបានធ្វើឡើងជាសង្ខេបអំពីការសម្រេចបានសំខាន់ៗរបស់ WGPD ដោយផ្តោតលើចំនុចសំខាន់ៗទាក់ទងនឹង (១) ការចូលរួមក្នុងដំណើរការការអភិវឌ្ឍតាមបែបជាធិបតេយ្យ (២) ការចុះឈ្មោះជាអង្គការថ្មី និង (៣) មូលនិធិគាំទ្រដល់ WGPD ។

បន្ទាប់ពីបទបង្ហាញបញ្ចប់ លោក **ជា វ៉ាន់ថា** បានពន្យល់បន្ថែមអំពីមូលនិធិគាំទ្រដល់ WGPD និងចំនុចមួយចំនួនទៀតទាក់ទងនឹងប្រភពថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងអនុញ្ញាតឲ្យអ្នកចូលរួមលើកជាសំណួរ

អំពីបទបង្ហាញ។ ចំពោះមូលនិធិគាំទ្រដល់ WGPD លោកបានពន្យល់អំពីគម្រោងបន្ទាប់ ដើម្បីស្វែងរកមូលនិធិគាំទ្របន្តដល់ WGPD នៅក្នុងផ្នែកនេះ អ្នកចូលរួមពុំមានជាសំណួរអ្វីឡើយ។

## ផ្នែកទី ២៖ បទបង្ហាញអំពីការសិក្សា និងការវិភាគលើការអនុវត្តគោលនយោបាយ

ផ្នែកនេះបង្ហាញដោយ លោក **ម៉ាន់ វ៉ាន់ផាន់និត** ជាប្រធានកម្មវិធីរបស់អង្គការ API ។ មុននឹងចាប់ផ្តើមធ្វើបទបង្ហាញ លោក ជា វ៉ាន់ថា នាយកអង្គការ API បានពិពណ៌នាដោយសង្ខេបអំពីប្រវត្តិអង្គការ API និង ការងារដែលអង្គការនេះធ្វើ។ បន្ទាប់មក លោក ម៉ាន់ វ៉ាន់ផាន់និត ក៏បានធ្វើបទបង្ហាញអំពីការសិក្សា និង ការវិភាគលើការអនុវត្តគោលនយោបាយលើករណីសិក្សាចំនួន ៧ មានដូចជា (១) តួនាទីអាជ្ញាធរក្នុងការបង្កបរិយាកាសឲ្យមានការចូលរួមជាសាធារណៈ (២) តួនាទីអាជ្ញាធរក្នុងការបើកចំហ និងផ្តល់សេវាសាធារណៈ (៣) តួនាទីរបស់ក្រុមប្រឹក្សាក្នុងការបើកចំហព័ត៌មានកញ្ចប់ថវិកា (៤) សិទ្ធិទទួលបានព័ត៌មានក្នុងវិស័យអប់រំ (៥) តួនាទីអាជ្ញាធរឃុំ/ស្រុកនៅក្នុងការចូលរួមក្នុងការការពារ និងអភិរក្សសហគមន៍ព្រៃឈើ (៦)តួនាទីអាជ្ញាធរឃុំ ស្រុកនៅក្នុងការលើកកម្ពស់សុវត្ថិភាពចរាចរណ៍ និង (៧)តួនាទីអាជ្ញាធរឃុំ ស្រុកនៅក្នុងការគ្រប់គ្រងកាក់សំណល់ ។

បទបង្ហាញនេះ ត្រូវបានធ្វើឡើងជារួម ដោយផ្តោតទៅលើចំនុចដូចខាងក្រោមនេះ៖ (១) ហេតុអ្វីធ្វើការសិក្សានេះឡើង (២) គោលបំណងនៃការសិក្សា (៣) ទំហំនៃការសិក្សា និងវិធីសាស្ត្រប្រមូលទិន្នន័យ (៤) របកគំហើញសំខាន់ៗ (៥) អនុសាសន៍ និង (៦) ផលប្រយោជន៍នៃរបាយការណ៍។

បន្ទាប់ពីបទបង្ហាញបញ្ចប់ អ្នកចូលរួមក៏បានលើកជាមតិយោបល់/សំនួរមួយចំនួនផងដែរ។ ការលើកជាមតិយោបល់ និងសំនួរមានតិចតួចនៅក្នុងផ្នែកនេះ ខាងក្រោមនេះ ជាមតិយោបល់/សំនួរ និងការបកស្រាយ។

**១. តាមការធ្វើបទបង្ហាញនេះ មានអនុសាសន៍ច្រើន តែគួរតែមានបញ្ចូលជំនាញទន់ផងដែរ ដើម្បីឲ្យពួកគាត់ (ក្រុមប្រឹក្សា) ចេះធ្វើការសម្របសម្រួលជាប្រជាពលរដ្ឋ។**

<u>បកស្រាយ</u>៖ ការពិតណាស់ យើងបានបញ្ចូលអនុសាសន៍នេះរួចហើយនៅក្នុងករណីសិក្សានៃរបាយការណ៍របស់យើង ដោយសារតែនេះ ជាបទបង្ហាញរួម ទើបអនុសាសន៍ទាំងនោះ ពុំមាននៅក្នុងបទបង្ហាញនេះ តាមពិត គឺមាន។

## ផ្នែកទី ៣៖ បទបង្ហាញអំពីក្របខ័ណ្ឌគុណតម្លៃនៃការរៀនសូត្រ

បទបង្ហាញនេះ ត្រូវបានពន្យល់ដោយលោក **ជួន ឈាន់** ជាអ្នកសម្របសម្រួលរបស់ WGPD ។ បទបង្ហាញនេះ ផ្តោតលើទ្រឹស្តីនៅក្នុងការចងក្រងការរៀនសូត្រកន្លងមក និងលក្ខណៈនៃចងក្រងការរៀនសូត្រដែលល្អ។

បន្ទាប់ពីបទបង្ហាញបញ្ចប់ អ្នកចូលរួមក៏បានលើកជាសំនួរមួយចំនួនផងដែរ ការលើកជាមតិយោបល់និងសំនួរមានតិចតួចនៅក្នុងផ្នែកនេះ ខាងក្រោមនេះ ជាសំនួរ និងការបកស្រាយ។

**១. តើបទបង្ហាញនេះ ធ្វើឡើងក្នុងគោលបំណងអ្វី?**

<u>បកស្រាយ</u>៖ បទបង្ហាញនេះ ធ្វើឡើងគឺចង់ឲ្យអ្នកចូលរួមចេះចងក្រងការរៀនសូត្រកន្លងមកយកមកចែករំលែកនៅក្នុងកិច្ចប្រជុំក្រោយៗទៀត។

**២. តើវាមានផលប្រយោជន៍អ្វី?**

<u>បកស្រាយ</u>៖ លោក ជា វ៉ាន់ថា បានពន្យល់ថា វាមានផលប្រយោជន៍ដោយសារដៃគូអភិវឌ្ឍចង់បានបែបនេះ ហើយវាជួយឲ្យយើងចេះសរសេរករណីសិក្សាបានល្អ អោយអ្នកដទៃទៀតអាចរៀនសូត្របានច្រើន។

## ផ្នែកទី ៤៖ បទបង្ហាញអំពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

នៅផ្នែកនេះ បង្ហាញដោយ **លោក លី ប៊ុនថៃ** ទីប្រឹក្សាគោលនយោបាយ គ.ជ.អ.ប ។ បទបង្ហាញនេះ គឺជាការវិវត្តថ្មីៗនៃកំណែទម្រង់D&D ទាក់ទងនឹងការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើ (១) ទិដ្ឋភាពទូទៅនៃការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (២) ការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ (៣) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (៤) ការរៀបចំ និង ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់ (៥) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក (៦) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង (៧) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ (៨) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (៩) ការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី និង (១០) អន្តរទំនាក់ទំនងក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ។

បន្ទាប់ពីបទបង្ហាញបញ្ចប់ អ្នកចូលរួមក៏បានលើកជាសំនួរមួយចំនួនផងដែរ។ ខាងក្រោមនេះ ជាសំនួរ និងការបកស្រាយ។

**១. ទាក់ទងនឹងប្រភពថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យើងមានមូលនិធិហិរញ្ញប្បទានវិនិយោគសម្រាប់ថ្នាក់ក្រោមជាតិ (SNIF) តើ SNIF ដំណើរការយ៉ាងណាដែរ?**

<u>បកស្រាយ</u>៖ SNIF នេះ យើងមានលុយប្រហែល ២០លានដុល្លា វាត្រូវបានអនុវត្តសម្រាប់តែថ្នាក់ស្រុកទេ។ គោលបំណងនៅក្នុងការអនុវត្ត SNIF នេះ គឺដើម្បីឲ្យរដ្ឋបាលស្រុកចេះប្រកួតប្រជែងគ្នា (រដ្ឋបាលស្រុកឯទៀត) យកថវិកានេះមកអនុវត្តគម្រោងនៅក្នុងស្រុករបស់ខ្លួន។

**២. ទាក់ទងនឹងសមត្ថភាពឃុំ តើយន្តការយ៉ាងណាដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់?**

<u>បកស្រាយ</u>៖ ក្រោយពីប្រកាសតែងតាំងចូលកាន់តួនាទីហើយ ក្រសួងមហាផ្ទៃនឹងរៀបចំវគ្គបណ្តុះបណ្តាលដល់មេឃុំ ក្រុមប្រឹក្សាឃុំដែលទើបនឹងជាប់ថ្មីទាំងអស់អំពី (១) កិច្ចការរដ្ឋបាល (២) ការរៀបចំ និងគ្រប់គ្រងហិរញ្ញវត្ថុ (៣) ការរៀបចំផែនការ និង (៤) ការជ្រើសរើសមេភូមិ។

**៣. តើ SNIF ខុសពី Social Fund យ៉ាងម៉េច?**

<u>បកស្រាយ</u>៖ ភាពខុសគ្នា គឺ SNIF អនុវត្តសម្រាប់តែថ្នាក់ស្រុក រីឯ Social Fund អនុវត្តសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទូទៅ។

**៤. តាមច្បាប់ ត្រូវមានចូលរួមរបស់ប្រជាពលរដ្ឋ ៦០% នៃគ្រួសារសរុប នៅក្នុងការរៀបចំផែនការឃុំ តែការអនុវត្ត ពុំបានតាមចំនួនកំណត់ទេ ហេតុអ្វីនៅតែចែង/សរសេរនៅក្នុងសេចក្តីណែនាំថ្មីនេះ?**

**<u>បកស្រាយ</u>៖** នៅក្នុងច្បាប់ចែងបែបនេះហើយ បើយើងមិនសរសេរវាបញ្ចូលទេ គឺខុស។ ការអនុវត្ត ពុំបានតាមចំនួនកំណត់ នោះជាការអនុវត្តទេ ជារឿងពីរផ្សេងគ្នា។

**៥. តើក្រុមប្រឹក្សា មានប្រាក់សោធននិវត្តន៍ដែរ ឬទេ?**

<u>បកស្រាយ</u>៖ អត់មានទេ ដោយសារក្រុមប្រឹក្សាជាមន្ត្រីនយោបាយ មិនមែនជាមន្ត្រីរាជការស៊ីវិលទេ។

មុននឹងថ្លែងបិទកិច្ចប្រជុំនេះ លោក **ជួន ឈាន់** បានថ្លែងអំណរគុណដល់សមាជិកដែលបានចំណាយពេលមកចូលរួមកិច្ចប្រជុំ និងបានសំដែងភាពសប្បាយរីករាយម្តងទៀត ដោយសមាជិកទទួលបានចំណេះដឹង អំពីការវិវត្តន៍ថ្មីៗនៃកំណែទម្រង់ D&D ជាពិសេសអំពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងនាមលេខាធិការដ្ឋាន WGPD រូបខ្ញុំផ្ទាល់នឹងព្យាយាមរកអ្នកដែលមានចំណេះដឹងទូលំលាយលើការងារកំណែទម្រង់ D&D ដើម្បីមកធ្វើការចែករំលែកចំណេះដឹងដល់សមាជិកនៅក្នុងកិច្ចប្រជុំក្រោយៗទៀត ជាចុងក្រោយ លោកបានថ្លែងបិទកិច្ចប្រជុំនេះ ។

**ឯកសារជូនភ្ជាប់មានដូចជា៖**

1. បញ្ជីវត្តមាន
2. របៀបវារៈនៃកិច្ចប្រជុំ
3. បទបង្ហាញ